ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ០៣១/២០ ក.ប/ស.ជ.ណ.ឌ.ហ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន សម្រាប់ពលករជំនាញផ្នែកថែទាំ ដើម្បីទៅធ្វើការនៅប្រទេសជប៉ុន

យោងតាមការជូនដំណឹងពីក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២០ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជូនដំណឹងដល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងទៅធ្វើការនៅប្រទេសជប៉ុន ក្នុងគម្រោងពលករជំនាញ ឱ្យបានជ្រាបថា អង្គភាពទទួលបន្ទុកការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន នឹងរៀបចំការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន សម្រាប់ផ្នែកថែទាំ (Nursing) ដែលមានព័ត៌មានលម្អិតដូចខាងក្រោម៖

➢ មណ្ឌលសម្រាប់ការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន មានពីរដូចខាងក្រោម៖

១. មណ្ឌលសកលវិទ្យាល័យអន្តរជាតិ ប៊ែលធី (សាខាទួលស្លែង)
- អាសយដ្ឋាន៖ ផ្ទះលេខ២១ ផ្លូវលេខ៣៦០ សង្កាត់បឹងកេងកង៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
- កាលបរិច្ឆេទការធ្វើតេស្ត ៖ នៅថ្ងៃទី១៣ និងទី១៤ ខែតុលា ឆ្នាំ២០២០
ចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី៦ និងនៅថ្ងៃទី១៤ និងទី១៥ ខែវិច្ឆិកា ឆ្នាំ២០២០
- លេខទូរស័ព្ទ៖ +855 78 221 222

២. មណ្ឌលវិទ្យាស្ថានអភិវឌ្ឍន៍វិស័យអប់រំ (EDI)
- អាសយដ្ឋាន៖ ផ្ទះលេខ៩A ផ្លូវលេខ៣៧០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ
- កាលបរិច្ឆេទការធ្វើតេស្ត ៖ នៅថ្ងៃទី២៣ និងទី២៤ ខែតុលា ឆ្នាំ២០២០
នៅថ្ងៃទី៧ ទី២០ និងទី២១ ខែវិច្ឆិកា ឆ្នាំ២០២០
- លេខទូរស័ព្ទ៖ +855 23 966 967 / +855 12 629 768 / +855 15 729 123

➢ ព័ត៌មានលម្អិតអំពីការចែកពាក្យ និងការចុះឈ្មោះធ្វើតេស្ត សូមចូលមើលគេហទំព័រខាងក្រោម៖

http://ac.prometric-jp.com/testlist/nc/en/index.html

➢ ការធ្វើតេស្តចែកជា ២ផ្នែក៖

១. ការធ្វើតេស្តវាយតម្លៃជំនាញថែទាំមានរយៈពេលសរុបចំនួន ៦០នាទី និងមាន ៤៥សំណួរ

ក. ការធ្វើតេស្តវិញ្ញាសាសរសេរ
- មូលដ្ឋានគ្រឹះនៃការថែទាំ មានចំនួន ១០សំណួរ
- ការយល់ដឹងផ្នែកអារម្មណ៍ និងរូបរាងកាយអ្នកជម្ងឺ មានចំនួន ៦សំណួរ

- ជំនាញទំនាក់ទំនងជាមួយអ្នកជម្ងឺ មានចំនួន ៤សំណួរ
- ការថែទាំផ្នែករាងកាយ មានចំនួន ២០សំណួរ

ខ. ការធ្វើតេស្តអនុវត្តជំនាញ៖ មាន៥សំណួរ

២. ការធ្វើតេស្តវាយតម្លៃភាសាជប៉ុន សម្រាប់ជំនាញថែទាំ មានរយៈពេលសរុបចំនួន ៣០នាទី និងមាន ១៥សំណួរ

ក. ពាក្យបច្ចេកទេសនៃការថែទាំ មាន ៥សំណួរ

ខ. ការទំនាក់ទំនងជាលក្ខណសន្ទនាសម្រាប់ផ្នែកថែទាំ មាន ៥សំណួរ

គ. ឯកសារទាក់ទងការថែទាំ មាន ៥សំណួរ

- ➢ ពិន្ទុដែលជាប់ការធ្វើតេស្ត គឺចាប់ពី៦០% នៃពិន្ទុសរុបទាំងអស់។
- ➢ ការធ្វើតេស្តគឺធ្វើឡើងតាមរយៈប្រព័ន្ធកុំព្យូទ័រ (CBT Method)។
- ➢ លទ្ធផលនៃការធ្វើតេស្ត នឹងត្រូវបានជូនដំណឹងមួយខែក្រោយ បន្ទាប់ពីកាលបរិច្ឆេទនៃការធ្វើតេស្ត។
- ➢ តម្លៃចុះឈ្មោះធ្វើតេស្ត៖ ២០០០យ៉េន (ប្រហែល២០ដុល្លារ) សម្រាប់តេស្តជំនាញ និងតេស្តភាសាជប៉ុន ផ្នែកថែទាំ
- ➢ លក្ខណសម្បត្តិចុះឈ្មោះធ្វើតេស្ត៖ ត្រូវមានអាយុចាប់ពី១៧ឆ្នាំ ឡើងទៅ ដោយមិនគិតពីកម្រិតវប្បធម៌
- ➢ **ឯកសារពាក់ព័ន្ធដែលត្រូវភ្ជាប់មកជាមួយរួមមាន៖**
  - អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរ ឬ
  - លិខិតឆ្លងដែន ឬ
  - ប័ណ្ណបើកបរ

<u>**បញ្ជាក់៖**</u> កាលបរិច្ឆេទនៃការធ្វើតេស្តនេះ អាចនឹងផ្លាស់ប្តូរអាស្រ័យទៅតាមស្ថានភាពជំងឺកូវីដ-១៩។ ក្នុងករណីមានការប្រែប្រួលណាមួយ ក្រសួងនឹងជូនដំណឹងបន្ថែមទៀត។

សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនងលេខទូរស័ព្ទ +603 76283371 (ប្រទេសជប៉ុន) រៀងរាល់ម៉ោងធ្វើការ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងចង់សុំចុះឈ្មោះធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន ជ្រាបតាមការគួរ។

ថ្ងៃ សុក្រ ៨កើត ខែ អស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

<u>**ចម្លងជូន**</u>

- -សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា(ACRA)
- -សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា(MAC)
- -ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ "ដើម្បីជួយផ្សព្វផ្សាយ និងសហការ"
- -ឯកសារ-កាលប្បវត្តិ